# ៦~ រឿង មាយាស្រី

ពីព្រេងនាយ មានបុរសម្នាក់ មានប្រពន្ធនៅជាមួយគ្នា តែពុំមានកូន ដល់យូរទៅប្រពន្ធនោះមានសហាយនាំមកដេកជាមួយក្នុងផ្ទះ តែសព្វថ្ងៃ ។

ថ្ងៃមួយ ប្ដីទៅជីកដំឡូងក្នុងព្រៃដល់ថ្ងៃក្ដៅចូលទៅអាស្រ័យនៅខ្ទមអ្នកតាមួយ ។ ប្រពន្ធរៀបឥវ៉ាន់ទៅបន់អ្នកតានោះ ឲ្យទៅធ្វើប្ដីឲ្យស្លាប់ និងយកសហាយធ្វើប្ដី រៀបស្រេចហើយ ក៏យកឥវ៉ាន់នោះដើរចូលទៅក្នុងខ្ទមអ្នកតា។ ប្ដីឃើញប្រពន្ធដើរចូលទៅក្នុងខ្ទមអ្នកតា ក៏នឹកឆ្ងល់ថា"ប្រពន្ធអញវាមករកអ្វីក្នុងខ្ទមអ្នកតានេះ"គិតហើយក៏ចូលទៅពួនក្រោយខ្នងរូបអ្នកតា លបស្ដាប់ប្រពន្ធ ។

ឯប្រពន្ធក៏ចូលទៅអុចទៀនធូប ហើយនិយាយបន់អ្នកតាថា"ខ្ញុំមិនចង់យកប្ដីខ្ញុំទេ ខ្ញុំយកប្ដីទៀត សូមអ្នកតាកាច់ប្ដីខ្ញុំឱ្យស្លាប់ទៅខ្ញុំនឹងថ្វាយជ្រូក១" ។

ប្ដីឮដូច្នោះ ក៏ឆ្លើយឡើងពីក្រោយអ្នកតាថា"អើបើនាងមានសហាយហើយចង់ឱ្យអញកាច់ប្ដីនាងស្លាប់នោះ ងាយទេ វិលទៅផ្ទះវិញ ត្រូវរកមាន់ក្រាបទាំងមេទាំងពងមួយសំបុកស្ងោរឱ្យប្ដីនាងស៊ីទៅ វាស្លាប់ហើយ" មេនោះឮដូច្នោះស្មានថា អ្នកតាបង្គាប់ក៏ប្រញាប់វិលរកទិញបានមេមាន់ក្រាបមួយសំបុកស្ងោរទុកឲ្យស៊ី ដើម្បីឱ្យស្លាប់ ហើយនឹងយកសហាយ ។

លុះដល់ព្រលប់ប្ដីមកពីជីកដំឡូងដល់ហើយសួរថា"គេហ៍អើយ ! បានអីស៊ីបាយ ?" ។ មេនោះឆ្លើយថា"ខ្ញុំបានមាន់ក្រាបមួយសំបុកស្ងោរទុកឲ្យអ្នក"ប្ដីថា "រៀបបាយមកស៊ី" ។ ប្រពន្ធក៏លើកបាយទាំងមាន់ក្រាបមកឱ្យប្ដីស៊ី ប្ដីស៊ីអស់មាន់ហើយធ្វើជាឈឺដេកថ្ងូរហ៊ឺៗ ។ មេនោះអរណាស់ គិតស្មានថាប្ដីឈឺមែន ត្រូវនឹងពាក្យអ្នកតាបង្គាប់ហើយដ្បិតឮថ្ងូរ ឯប្ដីក៏ធ្វើជាដេកទៅ មេនោះគិតស្មានថាប្ដីស្លាប់ ក៏បើកទ្វារនាំយកសហាយចូលទៅដេកជាមួយ ។ អ្នកទាំងពីរកំពុងតែនិយាយគ្នា ប្ដីក៏ក្រោកឡើងអង្គុយហៅប្រពន្ធមកប្រាប់ថា"រងារណាស់" ។

ឯបុរសសហាយ ឃើញប្ដីមេនោះក្រោកឡើងអង្គុយដូច្នោះស្ទុះរត់ពុំទាន់ក៏ចូលទៅពួនក្នុងពាងធំមួយនៅខាងដំណេក សំងំចាំប្ដីនោះដេកខ្លួននឹងចេញពីពាងនោះទៅដេកនឹងស្រីនោះទៀត ។

ប្ដីបានឃើញតែធ្វើជាមិនឃើញមិនដឹង ប្រាប់ប្រពន្ធថា"រងារណាស់ ឯងដាំទឹកឲ្យគ្នាមុជទឹកបន្តិចនឹងអាលស្លាប់" មេនោះឮថា ចង់ស្លាប់ដូច្នោះអរណាស់ដ្បិតត្រូវនឹងពាក្យ ដែលទៅបន់អ្នកតា ។

លុះប្រពន្ធដាំទឹកពុះហើយ ប្ដីថា"ទៅដងទឹកត្រជាក់បាន១ក្អមមកយកមកលាយនឹងទឹកក្ដៅនោះ" ។ ប្រពន្ធឮប្ដីប្រើដូច្នោះ ក៏យកក្អមចេញទៅដងទឹក ។ ប្ដីឃើញប្រពន្ធទៅបាត់ក៏ក្រោកឡើង ដើរទៅលើកទឹកពុះ១ខ្ទះនោះយកទៅស្រោចលើសហាយនៅក្នុងពាងនោះស្លាប់ទៅ ហើយចូលទៅដេកធ្វើជាឈឺថ្ងូរហ៊ឺៗទៀត ។

មេនោះវិលពីដងទឹកវិញ មើលទៅឃើញសហាយត្រូវទឹកក្ដៅរួញសរសៃដូចគេដកកចេញពីពាងមក ក៏អោនខ្សឹបថា"ថ្វីក៏មិនអោនទៅ វាមិនទាន់ដេកទេ" ។ អានោះនៅឆ្ងក់ដដែល មេនោះយកដៃទៅចាប់ច្រមុះទៅត្រូវស្លឹកត្រចៀករហែកជ្រុះទាំងសក់បានដឹងជាប្ដីស្រោចទឹកក្ដៅស្លាប់សហាយទៅហើយ ក៏ពុំស្ដីយកគ្របពាងមកគ្របហើយយកទឹកមកឲ្យប្ដីងូត ។ ឯប្ដីក៏មិនស្ដី ទិកក៏មិនងូត ប្រាប់ប្រពន្ធថា"អញគ្រាន់បើហើយ" ហើយហៅប្រពន្ធចូលដេកទៅ ។

លុះព្រឹកព្រហាមឡើង មេនោះពុំដឹងធ្វើដូចម្ដេចនឹងយកខ្មោចចេញឲ្យរួចផុតពីផ្ទះ ក៏នឹកឃើញថា" ក្នុងស្រុកនេះមានចោរ៤នាក់ តែងតែលបលួចអីវ៉ាន់អ្នកផងតែសព្វថ្ងៃ គ្រប់ភូមិ ដូច្នេះអញនឹងគិតឱ្យចោរទាំង៤នាក់នោះយកខ្មោចចេញពីផ្ទះអញទៅចោលក្នុងព្រៃឱ្យបាន" គិតហើយក៏ដើរខ្ចីសំពត់ហូល អាវព្រៃគេយកមកហាលជុំផ្ទះ ។ ឯចោរទាំង៤នាក់នោះឃើញហើយគិតថា" ជើ! មេនេះមានណាស់តើ! យប់នេះយើងនឹងទៅលួចវាឲ្យបានកុំខាន សព្វថ្ងៃយើងស្មានតែវាក្រ" ។

មេនោះក៏ហាលសំពត់ហាលអាវព្រៃនោះ លុះដល់ពេលល្ងាចយកទៅជូនគេវិញ ហើយយកខ្សែចងរឹតរួតពាងខ្មោចឱ្យជាប់ទុកឱ្យចោរចូលមកសែងយកទៅ ។

ឯចោរ៤នាក់លុះយប់ក៏បបួលគ្នាទៅលួច ចូលទៅរករបស់ទាំងនោះពុំឃើញៗតែពាងមួយចងមាត់ចាប់បើកពុំរួច ។ ចោរទាំង៤នាក់និយាយគ្នាថា " របស់អស់នេះវាដាក់ក្នុងពាងនេះហើយ បើដូច្នេះយើងត្រូវសែងពាងនេះ" ថាហើយក៏នាំគ្នាសែងពាងនេះទៅដល់ព្រៃឆ្ងាយក៏ស្រាយលូកមើល ។

អា១លូកដៃទៅត្រូវសក់ ថារ៉ុយសូត្រ ដកដៃចេញ ។ អា១លូកដៃទៅត្រូវស្លឹកត្រចៀក ត្រូវភ្នែក ច្រមុះ ស្រែកថារ៉ុយខ្មោចទេ ។ អា១មិនជឿក៏លូកដៃទៅទៀតត្រូវដើមទ្រូងដឹងថាខ្មោចមែន ក៏ស្ទុះរត់ចោល ហើយខឹងណាស់ថា ដ្បិតមេនោះបញ្ឆោតឱ្យសែងខ្មោចចោលបាន ។ ចោរទាំង៤នាក់គិតគ្នាថា "យើងឃ្លាំមើលមេនោះ បើឃើញវាដើរម្នាក់វា ត្រូវគ្នាយើងចោមរោមចាប់វាវាយឱ្យវារាង កុំឱ្យវាបញ្ឆោតយើងទៀត" ។

ជួនជាថ្ងៃមួយ មេនោះចុះទៅរកទិញអីវ៉ាន់ ដ្បិតមានសំពៅទើបនឹងមកដល់ ពីស្រុកក្រៅ ។ មេនោះដើរដល់ពាក់កណ្ដាលផ្លូវ ក៏ជួបចោរទាំង៤នាក់នោះ ចោរឃើញក៏នាំគ្នាព្រួតគ្នាចាប់នឹងវាយ ហើយជេរពីរឿងដែលវាបញ្ឆោតនោះ ។ មេនោះឆ្លើយថា "ណ្ហើយអ្នក បើអ្នកវាយខ្ញុំក៏ឥតប្រយោជន៍ដែរ ដ្បិតខ្ញុំទៅទារប្រាក់ពីនាយសំពៅ ដូច្នេះមក! អញ្ជើញទៅនឹងខ្ញុំៗទារប្រាក់បានចែកគ្នាចាយលេង" ។

ចោរទាំង៤នាក់ឮថាវាទៅទារប្រាក់ដូច្នោះ ក៏ចូលចិត្តបបួលគ្នាទៅ ។ មេនោះផ្ដាំចោរទាំង៤នាក់ថា " អស់អ្នកឈរចាំខ្ញុំនៅលើច្រាំងចុះ បើកាលណាឃើញខ្ញុំបោយដៃនោះអ្នកចុះទៅចុះបានប្រាក់ហើយ" ។

មេនោះនិយាយផ្ដាំចោរទាំង៤នាក់ហើយ ក៏ចុះទៅសំពៅ និយាយនឹងនាយសំពៅ លក់ចោរទាំង៤នាក់ វាថាចោរនោះជាខ្ញុំរបស់វា ហើយចង្អុលបង្ហាញនាយសំពៅថា " នុ៎ះហ្ន៎! វាទាំង៤នាក់បើវាចុះមកខ្ញុំឡើងទៅលើគោក សូមអ្នកចាប់វាដាក់ច្រវាក់ឲ្យជាប់ទៅ កុំឲ្យវារត់រួចបាន" ។ នាយសំពៅព្រមហើយសួរថា " ខ្ញុំនាងឯងទាំង៤នាក់លក់ថ្លៃប៉ុន្មាន ?" ។ មេនោះថា " ម្នាក់ថ្លៃ២ណែន" ។ នាយសំពៅឲ្យ១ណែនកន្លះ វាក៏ព្រមលក់ ហើយចេញមកក្រៅ បក់ដៃហៅចោរទាំង៤នាក់ ។ ចោរទាំង៤នាក់គិតស្មានថា វាហៅឲ្យទៅយកប្រាក់ក៏នាំគ្នាចុះទៅដល់ហើយស្រាប់តែនាយសំពៅប្រើមនុស្សឲ្យចាប់ដាក់ច្រវាក់ នៅបាតសំពៅទាំងអស់គ្នា ។ មេនោះក៏យកប្រាក់ឡើងមកបាត់ ។

បានប្រាក់ហើយមេនោះដើរវិលមកផ្ទះវិញ ដល់កណ្ដាលផ្លូវចូល ចួនជាយប់ពុំហ៊ានដើរទៅទៀតក៏ឡើងទៅដេកលើដើមឈើធំមួយនៅប្របផ្លូវនោះ ។

ឯចោរ៤នាក់នាយសំពៅដាក់ច្រវាក់ជាប់ហើយក៏និយាយគ្នាថា " ដើ! មេនោះហៅពេញជាប្រាជ្ញធំ វាបញ្ឆោតឲ្យយើងសែងខ្មោចទៅ ចោលក្នុងព្រៃ ហើយឥឡូវវាលក់យើងបានទៀត" ។ ចោរទាំង៤នាក់ខឹងណាស់កាច់ច្រវាក់បាក់រត់ចេញពីសំពៅដើរឡើងមកលើគោក រត់មកទាំងយប់នោះ ជួនជាយប់យូរណាស់ក៏នាំគ្នាឡើងទៅដេកលើដើមឈើធំ ដែលមេនោះដេក ។ ចោរ៣នាក់ឡើងដេកលើមែកដោយខ្លួន ។ ចោរម្នាក់ឡើងទៅក៏ជួបមេនោះ នៅលើចុងឈើ ។ អាចោរនោះថា " អើហាងឯងស្លាប់ហើយម្ដងនេះ ហាងឯងធ្លាប់តែបញ្ឆោតយើង ឥឡូវហាងឯងរត់ចុះបើរួច" ។

មេនោះលើកប្រាក់បង្ហាញហើយខ្សឹបថា " ណ្ហើយអ្នកកុំស្ដី កុំឲ្យអ្នកទាំង៣នាក់ដឹង យើងត្រូវយកគ្នាជាប្ដីប្រពន្ធ ហើយយកប្រាក់នេះទៅចាយរកស៊ីស្រួលជាង អ្នកកុំធ្វើបាបខ្ញុំធ្វើអ្វី" ។

អាចោរឮដូច្នោះក៏មិនស្ដីខិតចូលទៅជិតលូកដៃអោបកៀកមេនោះថា " អើ! ប្អូនឯងហៅប្រាជ្ញធំ បញ្ឆោតបងពីរដងហើយ ឥឡូវបងបាននាងជាប្រពន្ធដោយសារព្រេងសំណាងយើង" និយាយហើយក៏អោបថើបៗ ។ មេនោះពុំប្រកែកហើយថា " ខ្ញុំក្រែងអ្នកស្រឡាញ់ខ្ញុំមិនស្មោះ ឯខ្ញុំស្រឡាញ់អ្នកស្មោះចិត្តមួយហើយ" ។ អាចោរនោះថា " បងស្រឡាញ់ស្មោះ ហើយនាងពុំដឹងចិត្តបង ចង់ឲ្យបងស្បត់ ឬឲ្យបងធ្វើម្ដេច ?" ។

មេនោះថា“ បើស្រឡាញ់ចិត្តមួយនឹងគ្នា មានតែលិទ្ធអណ្តាតគ្នា” ទើបមេនោះលៀនអណ្តាតហើយអោនទៅរកចោរនោះ ។ ឯអាចោរលិទ្ធអណ្តាតមេនោះហើយលៀនអណ្តាតឲ្យមេនោះលិទ្ធវិញ ។ មេនោះខាំអណ្តាតអាចោរនោះដាច់អស់មួយកំណាត់ ហើយច្រានទំលាក់ពីលើចុងឈើធ្លាក់ដល់ដីស្រែកឮតែឡុលៗ ។

ឯចោរ៣នាក់គិតស្មានថា នាយសំពៅចោមចាប់ ក៏លោតពីមែកឈើរត់ទៅ ហើយស្រែកហៅគេថា“ វើរ គ្នាយើងរត់ នាយសំពៅដេញហើយ” ។ អាចោរដែលដាច់អណ្តាតនោះស្រែកហៅគ្នាវាថា“ មេនោះនៅលើចុងឈើត្រូវមកចាប់ ប៉ុន្តែវាដាច់អណ្តាតនិយាយមិនច្បាស់ឮតែឡុលៗ គ្នាវាគិតស្មានថាគេដេញចាប់ចេះតែរត់យកប្រាសអាយុរៀងៗខ្លួន” ។

ឯមេនោះចុះពីលើចុងឈើយកប្រាក់ទៅផ្ទះឲ្យប្តី នៅរកស៊ីជាមួយនឹងប្តីជាសុខសប្បាយទៅ ។

## អ្នកមានប្រាជ្ញាតែងតែអាត្មាឱ្យសុខចម្រើន